# តក្កកម្ម និងប្រកាសនីយបត្រតក្កកម្ម
# PATENTS

# ក. ប្រកាសនីយបត្រតក្កកម្មជាតិ

ដើម្បីទទួលបាននូវការការពារ គ្រប់ការរកឃើញថ្មីទាំងឡាយ ដាច់ខាតត្រូវតែស្នើសុំចុះបញ្ជី ហើយដែលបែបបទក្នុងការស្នើសុំត្រូវមានដូចជា ពាក្យសុំ សេចក្តីអធិប្បាយ សេចក្តីអះអាង ខ្លឹមសារសង្ខេប ជាអាទ៏។

# ក១. ពាក្យសុំ

ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ ពីអត្តសញ្ញាណនៃតក្កកម្ម គឺជាកិច្ចដំបូងគេបង្អស់នៅក្នុងការរៀបចំនូវសំណុំលិខិតស្នើសុំ រួមទាំងទិន្នន័យទាំងឡាយណាដែលពាក់ព័ន្ធនិងតក្កកម្ម ត្រូវភ្ជាប់មកជាមួយផងដែរនូវចំណាងជើងនៃតក្កកម្មនោះ។ ហើយប្រសិនបើអ្នកដាក់ពាក្យសុំនោះ មិនមែនជាតក្កករទេនោះ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់ពីការផ្ទេរសិទ្ធិមកជាមួយ។

(មាត្រា១៦-១៧)

# ក២. សេចក្តីអធិប្បាយ

តម្រូវឲ្យធ្វើការបកស្រាយពីតក្កកម្មនោះ ឲ្យបានច្បាស់លាស់ និងមានលក្ខណៈពេញលេញ ដើម្បីអាចឲ្យបុគ្គលដែលមានកម្រិតជំនាញធម្មតាអាចយល់ និងអាចអនុវត្តនូវតក្កកម្មនោះបាន។ម្យ៉ាងវិញទៀត ក៏ត្រូវចង្អុលបង្ហាញនូវវិធីសាស្ត្រដែលងាយយល់ ឬ ងាយស្រួលបំផុត អាចឲ្យគេអនុវត្តនូវតក្កកម្មនោះបាន។

(មាត្រា ១៨)

# ៣៣. សេចក្តីអះអាង

- ត្រូវកំណត់ឲ្យបានច្បាស់លាស់ចំពោះចំណុច ដែលចង់សុំឲ្យមានការការពារ ហើយជាងនេះទៅទៀតក៏អាចតម្រូវឲ្យប្រើប្រាស់នូវសេចក្តីអធិប្បាយ និងគំនូរបង្ហាញដើម្បីធ្វើការបកស្រាយពីសេចក្តីអះអាងរបស់ខ្លួន
- សេចក្តីអះអាងត្រូវតែច្បាស់លាស់ និងសង្ខេប
- គួរចង់ចាំថា សេចក្តីអះអាងពឹងផ្អែកទាំងស្រុងលើសេចក្តីអធិប្បាយ (ម.១៩)

# ៣៤. ខ្លឹមសារសង្ខេប

បកស្រាយត្រឹមតែពីព័ត៌មានបច្ចេកទេស ដែលទាក់ទងទៅនឹងតក្កកម្មនោះតែប៉ុណ្ណោះ ជាពិសេសទៅទៀតនោះ អ្នកដាក់ពាក្យស្នើសុំ មិនត្រូវធ្វើការបកស្រាយអំពីវិសាលភាពនៃការការពាររបស់តក្កកម្មនោះឡើយ (ម ២១)

# ចំណាំ

ទាំងនេះ ជាលក្ខខណ្ឌមួយចំនួនដែលតម្រូវឲ្យមាននៅក្នុងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ហើយក៏នូវមានចំណុចមួយចំនួនទៀត ដូចជាការរួមបញ្ចូលគ្នាតែមួយនៃតក្កកម្ម ការកែតម្រូវ និងការបំបែកសំណុំលិខិតស្នើសុំ ជាអាទិ៍។ (ម ២២-២៦)

# ៧. ប្រកាសនីយបត្រតក្កកម្មបរទេស

- តក្កកម្មដែលរកឃើញនោះ មិនស្ថិតនៅ ក្នុងប្រទេសដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មឡើយ។

- អ្នកដាក់ពាក្យសុំ ត្រូវផ្តល់ជូនដល់មន្ត្រីកាន់កាប់បញ្ជីនូវកាលបរិច្ឆេទ និងលេខនៃសំណុំលិខិតស្នើសុំទាំងឡាយដែលខ្លួនបានដាក់នៅឯបរទេស ហើយដែលវាពាក់ព័ន្ធទៅនឹងតក្កកម្មដូចគ្នា ឬ ស្ទើរតែដូចគ្នា ដូចដែលបានធ្វើការអះអាងនៅក្នុងសំណុំលិខិតស្នើសុំ។

# ៧. ប្រកាសនីយបត្រតក្កកម្មបរទេស(ត)

អ្នកដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មបរទេស ត្រូវបំពេញនូវសំណុំបែបបទមួយចំនួនដូចខាងក្រោម:

- ភ្ជាប់មកជាមួយនូវ ឯកសារចម្លងនៃលិខិតឆ្លើយឆ្លងដែលពាក់ព័ន្ធទៅនឹងលទ្ធផលនៃការស្រាវជ្រាវ ឬ លទ្ធផលនៃការពិនិត្យសំណុំលិខិតស្នើសុំនៅឯបរទេស ដែលអ្នកដាក់ពាក្យសុំបានទទួល

# ១. ប្រកាសនីយបត្រតក្កកម្មបរទេស (ត)

- ឯកសារចម្លងនៃប្រកាសនីយបត្រតក្កកម្មដែល បានផ្ដល់ឲ្យតាមការដាក់ពាក្យសុំនៅឯបរទេស

- ឯកសារចម្លងនៃសេចក្ដីសម្រេចចុងក្រោយ ដែលបានបដិសេធមិនទទួលនូវសំណុំលិខិតស្នើសុំនៅឯបរទេស ឬការបដិសេធមិនផ្ដល់ជូននូវប្រកាសនីយបត្រតក្កកម្ម តាមសំណើនៃសំណុំលិខិតស្នើសុំនោះ

# កាលបរិច្ឆេទនៃពាក្យសុំចុះបញ្ជី

មន្ត្រីកាន់កាប់បញ្ជី ត្រូវទទួលស្គាល់នូវកាលបរិច្ឆេទនៃការទទួលសំណុំលិខិតស្នើសុំ ថាជាកាលបរិច្ឆេទនៃការសុំចុះបញ្ជីសំណុំលិខិតស្នើសុំបាន លុះត្រាតែនៅពេលដែលទទួលសំណុំលិខិតស្នើសុំនោះបានបំពេញនូវឯកសារត្រឹមត្រូវ ដូចដែលបានកំណត់ខាងក្រោម ៖

# កាលបរិច្ឆេទនៃពាក្យសុំចុះបញ្ជី

១. ការបញ្ជាក់យ៉ាងច្បាស់លាស់ ឬ គ្រប់គ្រាន់ អំពីបំណងនៃការសុំផ្តល់នូវប្រកាសនីយបត្រតក្កកម្ម

២. ការបញ្ជាក់អំពីអត្តសញ្ញាណនៃអ្នកដាក់ពាក្យស្នើសុំ

៣. សំណុំលិខិតស្នើសុំនោះ ត្រូវមានសេចក្តីអធិប្បាយអំពីតក្កកម្ម

# ការពិនិត្យពាក្យសុំ

នៅពេលដែលទទួល នូវសំណុំលិខតិស្នើសុំប្រកាសនីយបត្រតក្កកម្ម មន្ត្រីទទួលបន្ទុកកាន់កាប់បញ្ជីពាក្យសុំ ត្រូវធ្វើការត្រួតពិនិត្យទៅលើលក្ខខណ្ឌរួម ខ្លឹមសារ និងទម្រង់បែបបទមួយចំនួន ដែលបានភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំនោះ

# ការផ្សព្វផ្សាយជាសាធារណៈ

- គឺមានសារៈសំខាន់ផងដែរ ព្រោះថា វាជាការបង្ហាញឲ្យមនុស្សទាំងអស់បានដឹងពី តក្កកម្ម និង តក្ករ។
- បុគ្គលទាំងឡាយ ដែលមានផលប្រយោជន៍ពាក់ព័ន្ធទៅនឹងតក្កកម្មនោះ អាចដាក់ពាក្យប្តឹងជំទាស់ពីការប្រគល់នូវប្រកាសនីយបត្រតក្កកម្មនេះបាន។
- ចុះផ្សាយពីសេចក្តីបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្មនោះ

# ការផ្សព្វផ្សាយជាសាធារណៈ

- ចេញលិខិតបញ្ជាក់ពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម ចម្លង់មួយច្បាប់ឲ្យដល់អ្នកដាក់ពាក្យសុំ
- កត់ត្រានូវប្រកាសនីយបត្រតក្កកម្មនោះ នៅក្នុងបញ្ជី
- ច្បាប់ចម្លងនៃប្រកាសនីយបត្រតក្កកម្ម ត្រូវមានសម្រាប់សាធារណៈអាចជាវតាមតម្លៃដែលបានកំណត់។

# រយៈពេលនៃការការពារ

- តក្កកម្មមួយ អាចទទួលបានការការពារ ក្នុងរយៈពេល ២០ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម។
- ផុតពីរយៈពេលដែលបានកំណត់នេះទៅ តក្កកម្មនោះ មិនអាចសុំពន្យារពេលនៃការការពារបានទេ ហើយវានឹងក្លាយទៅជាទ្រព្យសាធារណៈ។

# សិទ្ធិដែលទទួលបាន

សិទ្ធិដែលទទួលបានពីប្រកាសនីយបត្រតក្កកម្ម គឺមានលក្ខណៈដាច់ខាត ផ្ដាច់មុខ (សិទ្ធិសេដ្ឋកិច្ច) និងសិទ្ធិដែលមានជារៀងរហូត ((សិទ្ធិសីលធម៌) ដែលសិទ្ធិនេះគ្មានអាជ្ញាយុកាលទេ)។

# ការធ្វើអាជីវកម្មដោយពុំចាំបាច់មានការអនុញ្ញា

- ករណីមួយចំនួន គេអាចធ្វើអាជីវកម្មលើតក្កកម្មនោះបាន ដោយពុំចាំបាច់មានការអនុញ្ញាតពីម្ចាស់សិទ្ធិឡើយ។
- ករណីនេះ ទោះបីជាមាន ឬ គ្មានការយល់ព្រម ពីម្ចាស់សិទ្ធិក៏ដោយ ក៏ពុំមែនជាបញ្ហាចោទដែរ មិនតែប៉ុណ្ណោះ ការធ្វើអាជីវកម្មទាំងនោះត្រូវបានចាត់ទុកថា ជាការធ្វើអាជីវកម្មដោយស្របច្បាប់។

# សំគាល់

- ❖ទោះជាយ៉ាងណាក៏ដោយ ក៏ផលប្រយោជន៍របស់តក្កករមិនត្រូវបានបាត់បង់ទេ ប្រសិនបើរដ្ឋធ្វើអាជីវកម្មដោយខ្លួនឯង នោះរដ្ឋត្រូវចេញសំណងជូសជុលការខូចខាតដល់តក្កករ ឬម្ចាស់សិទ្ធិ។
- ❖បើអាជីវកម្មធ្វើឡើងដោយតតិយជន នោះតតិយជនគឺជាអ្នកទទួលខុសត្រូវលើបន្ទុកនៃសំណងដល់ម្ចាស់សិទ្ធិ ទៅតាមតម្លៃសេដ្ឋកិច្ច ហើយជាពិសេសការធ្វើអាជីវកម្មរបស់តតិយជននោះត្រូវតែគោរពតាមកម្មវត្ថុដែលបានអនុញ្ញាត។

# សំគាល់

អាចធ្វើអាជីវកម្មបាន លុះណាតែបានគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- ជាសេចក្តីតម្រូវចាំបាច់សម្រាប់ប្រយោជន៍សាធារណៈ ជាពិសេសផ្នែកសន្តិសុខ អាហារូបត្ថម សុខាភិបាល និងក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ
- តុលាការមានសមត្ថកិច្ចបានសម្រេចថា របៀបនៃការធ្វើអាជីវកម្មរបស់តក្កករ ឬ ការធ្វើអាជីវកម្មដោយជនដែលទទួលបាននូវអាជ្ញាប័ណ្ណនោះមានលក្ខណៈ ប្រឆាំងនឹការប្រកួតប្រជែងដោយស្មោះត្រង់

# អំពើរលោភសិទ្ធិ

- មាត្រា១២៥ (យោងមាត្រា៩១ ដល់ ៩៩) ដល់ ១២៨

# ឧទាហរណ៍

- មាត្រា ១៣២
- មាត្រា ១៣៣
- មាត្រា ១៣៤
- មាត្រា ១៣៥

# IS IT POSSIBLE TO GET WORLDWIDE PATENT?

ANSWER = ?

# HOW TO GET INTERNATIONAL PROTECTION?

THE INTERNATIONAL AGREEMENT ADMINISTERED BY WIPO CALLED THE PATENT COOPERATION TREATY (PCT), FOR THE FILING, SEARCHING, PUBLICATION AND EXAMINATION OF INTERNATIONAL APPLICATIONS. THE PCT MAKES IT EASIER TO OBTAIN PATENTS IN THE CONTRACTING STATES BY PROVIDING FOR THE FILING OF ONE INTERNATIONAL APPLICATION, WHICH MAY BE SUBSEQUENTLY PROSECUTED IN THE DIFFERENT DESIGNATED NATIONAL OR REGIONAL OFFICES OF STATES PARTY TO THE PCT.

# THE END